ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១២១/១៣-អឹម វ៉េ (សាខាទី៣)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ម៉ែន និម្មិត**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ក្រុមហ៊ុន អឹម វ៉េ កាត់ដេរអន្តរជាតិ (សាខាទី៣)**

អាសយដ្ឋាន ៖ អគារលេខ១៦២៣ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៦ ៧០ ៧០ ៤៦ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមប្រជុំមុនសវនាការ ៖

១- លោក យិន ណាក់ — រដ្ឋបាល

២- លោក ឡុង ប៊ាង — មន្ត្រីសមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC)

### ២- ភាគីកម្មករនិយោជិត

ក/ឈ្មោះ ៖ - **សហព័ន្ធសហជីពឯករាជ្យកម្ពុជា**

- **សហជីពឯករាជ្យកម្មករ នៃក្រុមហ៊ុន អឹម វ៉េ កាត់ដេរកម្ពុជា (សាខាទី៣)**

អាសយដ្ឋាន ៖ អគារលេខ១៦២៣ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៤៣ ៧០ ៨៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh ◆ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org ◆ Website: www.arbitrationcouncil.org

១- លោកស្រី ទេព គីមវណ្ណារី ប្រធានសហព័ន្ធសហជីពឯករាជ្យកម្ពុជា

២- លោក ជា រ័ត្ន មន្ត្រីសហព័ន្ធសហជីពឯករាជ្យកម្ពុជា

៣- លោក លោន ស៊ីថា ប្រធានសហជីពឯករាជ្យកម្មករ នៃក្រុមហ៊ុន M & V 3

ខ/ឈ្មោះ ៖ - **សហព័ន្ធសហជីពឧស្សាហកម្មកម្ពុជា**

**- សហជីពឧស្សាហកម្មកម្ពុជា នៃក្រុមហ៊ុន អឹម វ៉េ កាត់ដេរកម្ពុជា (សាខាទី៣)**

អាសយដ្ឋាន ៖ អគារលេខ១៦២៣ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៦៩៩ ៣៩៥ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖

១- លោក ហែម សុខពន្លក ប្រធានសហព័ន្ធសហជីពឧស្សាហកម្មកម្ពុជា

២- លោក ហ៊ីន ម៉ៃ ប្រធានសហជីពឧស្សាហកម្មកម្ពុជា នៃក្រុមហ៊ុន M & V 3

៣- លោក នួន សុភាព អនុប្រធានសហជីពឧស្សាហកម្មកម្ពុជា នៃក្រុមហ៊ុន M & V 3

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ថ្នាក់ដឹកនាំសហជីពឯករាជ្យកម្ពុជា និងថ្នាក់ដឹកនាំសហជីពឧស្សាហកម្មកម្ពុជា ប្រចាំក្រុមហ៊ុន អឹម វ៉េ កាត់ដេរអន្តរជាតិ (សាខា ទី៣) ស្នើសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ធ្វើដំណើរចំនួន ១០ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការទាមទារបានទេ ក្រុមហ៊ុនអនុវត្តទៅតាមសេចក្តីជូនដំណឹង របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ២៣០ ក.ប/ស.ជ.ណ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២។

២- ថ្នាក់ដឹកនាំសហជីពឯករាជ្យកម្ពុជា និងថ្នាក់ដឹកនាំសហជីពឧស្សាហកម្មកម្ពុជា ប្រចាំក្រុមហ៊ុន ស្នើសុំឱ្យក្រុមហ៊ុនរក្សាប្រាក់ទ្រទ្រង់សុខភាព ៥ ដុល្លារ ក្នុងមួយខែ បន្ថែមលើប្រាក់គោលដែលកំណត់ដោយច្បាប់ ដោយហេតុថា មានកម្មករសន្លប់ច្រើន ដោយសារខ្វះខាតជីវភាព និងបានយកទៅបន្ថែមលើជីវភាពដើម្បីសុខភាពកាន់តែល្អ ដើម្បីធ្វើការឱ្យក្រុមហ៊ុន។ ដោយឡែកភាគីក្រុមហ៊ុនអនុវត្តតាមសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ១០៣ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣។

៣- ថ្នាក់ដឹកនាំសហជីពឯករាជ្យកម្ពុជា និងថ្នាក់ដឹកនាំសហជីពឧស្សាហកម្មកម្ពុជា ប្រចាំក្រុមហ៊ុន ស្នើសុំឱ្យក្រុមហ៊ុនតំឡើងប្រាក់អតីតភាពការងារសម្រាប់កម្មករលើសពី ១១ ឆ្នាំឡើងទៅ ក្នុង១ឆ្នាំ ១ ដុល្លារ បូកបន្ថែមជារៀងរាល់ឆ្នាំ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការស្នើសុំបានទេ ក្រុមហ៊ុនអនុវត្តតាមសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១។

THE ARBITRATION COUNCIL

៤- ថ្នាក់ដឹកនាំសហជីពឯករាជ្យកម្ពុជា និងថ្នាក់ដឹកនាំសហជីពឧស្សាហកម្មកម្ពុជា ប្រចាំក្រុមហ៊ុន សូមឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៦ ដុល្លារ ដល់កម្មករកិច្ចសន្យាកំណត់ថេរវេលា ឱ្យដូចកម្មករមិនកំណត់ថេរវេលា។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការស្នើសុំបានទេ។

៥- ថ្នាក់ដឹកនាំសហជីពឯករាជ្យកម្ពុជា និងថ្នាក់ដឹកនាំសហជីពឧស្សាហកម្មកម្ពុជា ប្រចាំក្រុមហ៊ុន ស្នើសុំឱ្យក្រុមហ៊ុនផ្តល់លុយបាយថែមម៉ោង ២ ម៉ោង ស្មើ ៣០០០ រៀល។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការទាមទារបានឡើយ។

៦- ថ្នាក់ដឹកនាំសហជីពឯករាជ្យកម្ពុជា និងថ្នាក់ដឹកនាំសហជីពឧស្សាហកម្មកម្ពុជា ប្រចាំក្រុមហ៊ុន ស្នើសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភថ្ងៃបុណ្យ ៣ ដុល្លារ ក្នុងមួយថ្ងៃ។ ដោយឡែកភាគីក្រុមហ៊ុនអនុវត្តទៅតាមគោលការណ៍កន្លងមក។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១២១ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១០)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៧០៩ ក.ប/អក/វក. ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទជួបប្រជុំមុនសវនាការ ៖** ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ (វេលាម៉ោង ១០ និង ៣០ នាទី ព្រឹក)។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងតាមទូរសារបស់ថ្នាក់ដឹកនាំសហជីពឯករាជ្យកម្ពុជា និងថ្នាក់ដឹកនាំសហជីពឧស្សាហកម្មកម្ពុជា ប្រចាំក្រុមហ៊ុន អឹម វ៉ី កាត់ដេរអន្តរជាតិ (សាខាទី៣) ស្តីពីកម្មករនិយោជិតធ្វើកូដកម្មទាមទារឱ្យក្រុមហ៊ុនដោះស្រាយនូវលក្ខខណ្ឌការងារមួយចំនួន ជូនកម្មករឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះភ្លាម នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីផ្សះផ្សាចុះដល់ទីតាំង

ARBITRATION COUNCIL

ក្រុមហ៊ុន និងផ្សះផ្សាវិវាទការងាររួមនេះ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៦ ចំណុច លើការទាមទារ ចំនួន ០៩ ចំណុច។ ចំណុចមិនសះជាចំនួន ០៦ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមលេខ ៧០៩ ក.ប/អក/វក. ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលលិខិតរបស់ក្រុមហ៊ុន អឹម វ៉េ កាត់ដេរអន្តរជាតិ សាខាទី៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីឱ្យកម្មករបញ្ឈប់ការធ្វើកូដកម្ម។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាលេខ ០២៦/១៣ កបអ. ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ឱ្យកូដករផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មនៅក្រុមហ៊ុន អឹម វ៉េ កាត់ដេរអន្តរជាតិ សាខាទី៣ រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៣ តទៅតាមវេនរបស់ខ្លួន។ កូដករនៅបន្តធ្វើកូដកម្មដដែល ដោយកូដករមិនបានគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ នៅវេលាម៉ោង ១០៖៣០ នាទី ព្រឹក។ ភាគីកម្មករនិយោជិត និងភាគីនិយោជក មានវត្តមាន តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ភាគីកម្មករនិយោជិតបានអះអាងថា ភាគច្រើននៃសមាជិករបស់ខ្លួនបានត្រលប់ចូលធ្វើការវិញហើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យភាគីកម្មករនិយោជិត ដាក់ភស្តុតាងជាបញ្ជីឈ្មោះជាមួយស្នាមមេដៃរបស់កម្មករនិយោជិតដែលបានត្រលប់ចូលធ្វើការវិញ ត្រឹមថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ប៉ុន្តែ មកដល់កាលបរិច្ឆេទនេះ ភាគីកម្មករនិយោជិតមិនបានដាក់បញ្ជីឈ្មោះនោះទេ ដើម្បីគាំទ្រការអះអាងរបស់ខ្លួនទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេចដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតរបស់ក្រុមហ៊ុន អឹម វ៉េ កាត់ដេរអន្តរជាតិ សាខាទី៣ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិត នៅក្រុមហ៊ុន អ៊ឹម វ៉េ កាត់ដេរអន្តរជាតិ សាខាទី៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ។

២- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន អ៊ឹម វ៉េ កាត់ដេរអន្តរជាតិ សាខាទី៣ ផ្ទេរសិទ្ធិជូន (១) លោក យិន ណាក់ ជាប្រធានរដ្ឋបាល (២) កញ្ញា វ៉ា ភីឡេង ជាជំនួយការនាយក និង (៣) លោក ឡុង ហ៊ាង ជាតំណាងសមាគមកាត់ដេរ ក្នុងការសម្រេច និងទំនាក់ទំនងដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន

អ៊ឹម វ៉េ កាត់ដេរអន្តរជាតិ សាខាទី៣ ជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អ៊ឹម វ៉េ កាត់ដេរអន្តរជាតិ (សាខាទី៣) លេខ ៧០៩ ក.ប/អក/វក. ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន អ៊ឹម វ៉េ កាត់ដេរអន្តរជាតិ (សាខាទី៣) ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០២៦/១៣ កបអ. ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០១៣។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ៦១៦ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣។

៣- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៦១៧ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ។

**អង្គហេតុ**

- មិនមានការរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលនាយកដ្ឋានវិវាទការងារ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា ៖ “*ក្នុងអំឡុងពេល នៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀតដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម។*

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការអាជ្ញាកណ្ដាល ។

នៅក្នុងសេចក្ដីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងមិនបន្តដំណើរការអាជ្ញាកណ្ដាលទេ នៅពេលណាភាគីកម្មករនិយោជិត កំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។ (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ *៥៩/០៦-សាង វ៉ូ លេខ៣៩/០៨-ចុង យ៉ូវ លេខ ១៣៧/០៩ និង ១៣៨/០៩-ញ៉ូ ភាញ៉ូ និង លេខ ១១០/១១- ស៊ីម៉ាណូ* ) ។

ឧទាហរណ៍ នៅក្នុងសំណុំរឿងលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្ដីជូនដំណឹងនេះ កំណត់ថា ៖

*" ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្ដាល ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្ដីបង្គាប់លើវិវាទការងាររួមនេះបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចដោះស្រាយវិវាទការងាររួមនេះម្ដងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម "*។

ដូចគ្នាដែរ នៅក្នុងសំណុំរឿងលេខ ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វល ប្រែគ្គឱ អង្គរ, សាន់វេ, អ៊ិនធើខនធីណេនថល និង សូហ្វីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបញ្ជាទីពីរ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៤ ត្រង់ចំណុចទី៩ និងទី១១ នៃសេចក្ដីបញ្ជានេះចែងដូចខាងក្រោម ៖

*" ចំណុចទី៩-ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬ ការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ "* ។

*" ចំណុចទី ១១-ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្ដាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្ដីបញ្ជានេះ "* ។

នៅក្នុងសំណុំរឿងលេខ ៧៧/០៥-ប្រ៊្វង់កូ នីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។

នៅក្នុងសំណុំរឿងលេខ ១១០/១១-ស៊ីម៉ាណូ និងសំណុំរឿងលេខ ១៧/១៣-អ៊ិនធើណាស្យូណាល់ ហ្វេសិនរ៉ូយ៉ាល់ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏បានចេញសេចក្ដីបង្គាប់មិនបន្តដំណើរការអាជ្ញាកណ្ដាល ដោយមូលហេតុ កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងអំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលដែរ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏យល់ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងខាងលើដែរ ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានកោះហៅភាគីទាំងពីរមកបំភ្លឺលើករណីកូដកម្មនេះ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១៣។ ភាគីកម្មករនិយោជិត និងភាគីនិយោជក មានវត្តមាន តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។

ភាគីកម្មករ និយោជិតបានអះអាងថា ភាគច្រើននៃសមាជិករបស់ខ្លួន បានត្រលប់ចូលធ្វើការវិញហើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យភាគីកម្មករនិយោជិត ដាក់ភស្តុតាងជាបញ្ជីឈ្មោះជាមួយស្នាមមេដៃរបស់កម្មករនិយោជិតដែលបានត្រលប់ចូលធ្វើការវិញ ត្រឹមថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ប៉ុន្តែ មកដល់កាលបរិច្ឆេទនេះ ភាគីកម្មករនិយោជិតមិនបានដាក់បញ្ជីឈ្មោះនោះទេ ដើម្បីគាំទ្រការអះអាងរបស់ខ្លួនទេ។ ដោយសារតែភាគីកម្មករនិយោជិតមិនបានផ្តល់ភស្តុតាងដើម្បីបញ្ជាក់ការអះអាងរបស់ខ្លួន ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្មតថា ភាគីកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ដោយមិនគោរពតាមសេចក្តីបញ្ជាលេខ ០២៦/១៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះទេ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

- មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ១២១/១៣-អឹម វ៉េ (សាខាទី ៣)។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ----------------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ----------------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **ម៉ែន និម្មិត**

ហត្ថលេខា ៖ ----------------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL